ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...០៧២......សហវ.........

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមសម្របសម្រួល នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០០៧ ស្តីពីការកែសំរួលការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញសេចក្តីសម្រេចលេខ ៥៦ សសរ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៧ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញប្រកាសលេខ ១២០ សហវ ប្រក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០០៨ ស្តីពីការកែសម្រួល ប្រកាសលេខ ២១៨ សហវ ប្រក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការបង្កើតគណៈកម្មាធិការកែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- យោងលើភាពចាំបាច់របស់គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

# សម្រេច

**ប្រការ ១.-**

បង្កើត «**ក្រុមសម្របសម្រួល នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**» ហៅកាត់ «**កសហ**» ដែលមានភារកិច្ចសម្របសម្រួលបច្ចេកទេសផ្ទៃក្នុងនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាសេនាធិការបច្ចេកទេសរបស់គណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

**ប្រការ ២.-**

«**កសហ**» មាន ៥ ក្រុម ដែលដឹកនាំដោយអគ្គលេខាធិការ ឬអគ្គលេខាធិការរងមួយរូប និងមានសមាសភាពដូចខាងក្រោម÷

**១-ក្រុមរៀបចំថវិកា**: ដឹកនាំដោយឯកឧត្តម **ទន់ សណ្ដាប់** អគ្គលេខាធិការរងនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ នាយកដ្ឋាន ដែលត្រូវសម្របសម្រួលរួមមាន: នាយកដ្ឋានថវិកា នាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការអន្តរជាតិ និងនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន ។

**២-ក្រុមចំណូល**: ដឹកនាំដោយឯកឧត្តម **ជុំ ទិដ្ឋិវត្ត** អគ្គលេខាធិការរងនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ អគ្គនាយកដ្ឋាន និងនាយកដ្ឋាន ដែលត្រូវសម្របសម្រួលរួមមាន: អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ និងនាយកដ្ឋានចំណូលមិនមែនសារពើពន្ធ ។

**៣-ក្រុមអនុវត្តថវិកា**: ដឹកនាំដោយឯកឧត្តម **ញឹម ខេមរា** អគ្គលេខាធិការរងនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ អគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាព ដែលត្រូវសម្របសម្រួលរួមមាន: អគ្គនាយកដ្ឋានរតនាគារជាតិ នាយកដ្ឋានហិរញ្ញកិច្ច នាយកដ្ឋានលទ្ធកម្មសាធារណៈ និងអង្គភាពគ្រប់គ្រងសាច់ប្រាក់ ។

**៤-ក្រុមគោលនយោបាយ**: ដឹកនាំដោយឯកឧត្តម **រស់ សីលវ៉ា** អគ្គលេខាធិការរងនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ នាយកដ្ឋាន និងអង្គភាព ដែលត្រូវសម្របសម្រួលរួមមាន: នាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ នាយកដ្ឋាននីតិកម្ម នាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ច និងអាស៊ាន អគ្គាធិការដ្ឋាន និងនាយកដ្ឋានព័ត៌មានវិទ្យា។

**៥-ក្រុមគាំទ្រ**: ដឹកនាំដោយឯកឧត្តម **ហ៊ាន សាហ៊ីប** អគ្គលេខាធិការរងនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ នាយកដ្ឋាន និងអង្គភាព ដែលត្រូវសម្របសម្រួលរួមមាន: នាយកដ្ឋានបុគ្គលិក នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងនាយកដ្ឋានសវនកម្មផ្ទៃក្នុង ។

**ប្រការ ៣.-**

**«គសហ»** មានភារកិច្ចសម្របសម្រួលបច្ចេកទេស លើការអនុវត្តផែនការសកម្មភាពការងារនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូល ពិសេសគឺមានសិទ្ធិអំណាចគ្រប់គ្រាន់ក្នុងការដឹកនាំ និងសម្របសម្រួលការអនុវត្តផែនការសកម្មភាពការងាររបស់អគ្គនាយកដ្ឋាន នាយកដ្ឋាន និង អង្គភាពដែលស្ថិតក្នុងក្រុមការងារនីមួយៗដូចមានចែងក្នុងប្រការ ២ ក្នុងនាមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្នុងនាមគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ស្របតាមលក្ខខណ្ឌយោងនៃក្រុមសម្របសម្រួលនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជាឧបសម្ព័ន្ធនៃសេចក្តីសម្រេចនេះ ។

**ប្រការ ៤.-**

សេចក្តីសម្រេចនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១០

**<u>ចំលងជូនៈ</u>**
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង- ស្ថាប័ន
- គ្រប់ថ្នាក់ដឹកនាំនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន នាយកដ្ឋាន និងគ្រប់អង្គភាពចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សាមីខ្លួន ដើម្បីអនុវត្ត
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធ

# នៃ

# សេចក្តីសម្រេចលេខៈ ០៣៤ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១០ ស្តីពីការបង្កើត ក្រុមសម្របសម្រួល នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

## លក្ខខណ្ឌយោង
## ក្រុមសម្របសម្រួល នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ក្រុមសម្របសម្រួល គឺជាសមាសធាតុដ៏សំខាន់មួយសម្រាប់ក្របខណ្ឌគ្រប់គ្រងនៃកំណែទម្រង់ទាំងមូល ដែលដើរតួនាទីគន្លឹះ សម្រាប់ភ្ជាប់ទំនាក់ទំនងរវាងសកម្មភាពកំណែទម្រង់ទៅនឹងគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ហើយដែលមានការទទួលខុសត្រូវសម្របសម្រួលការអនុវត្តផែនការសកម្មភាពកែទម្រង់ទាំងមូល ។ ក្រុមសម្របសម្រួលមានសិទ្ធិអំណាចគ្រប់គ្រាន់ ដើម្បីដឹកនាំការងារអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅក្នុងអគ្គនាយកដ្ឋាន នាយកដ្ឋាន អង្គភាពនានា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ក្រុមសម្របសម្រួលនីមួយៗបំពេញការងារនៅក្នុងក្របខណ្ឌនៃគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងមានការទទួលខុសត្រូវរួម និងសិទ្ធិអំណាចក្នុងការអនុវត្ត និងសម្របសម្រួលសកម្មភាពកែទម្រង់រវាងអគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពនានា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលស្ថិតនៅក្នុងក្រុមសម្របសម្រួលនីមួយៗ ។

### I- តួនាទី

១. បំពេញការងារក្នុងនាមគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទៅតាមមុខងារដែលត្រូវបានផ្តល់ជូន ដើម្បីធានាឱ្យមានភាពស៊ីសង្វាក់គ្នាប្រកបដោយប្រសិទ្ធភាពរវាងផែនការសកម្មភាពកំណែទម្រង់ទាំងមូល និងផែនការសកម្មភាពដែលត្រូវអនុវត្តដោយអគ្គនាយកដ្ឋាន នាយកដ្ឋាន អង្គភាពនានា និងក្រសួង ស្ថាប័ន ។

២. ធានាថាផែនការសកម្មភាពលម្អិតដែលរៀបចំដោយអគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពនានា មានលក្ខណៈល្អគ្រប់គ្រាន់ និងឆ្លើយតបទៅតាមគោលបំណងជាយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ ។

៣. បំពេញតួនាទីជាសេនាធិការគណៈកម្មការកែទម្រង់ និងលើកឡើងពីបញ្ហានានាដែលមិនអាចដោះស្រាយបានត្រឹមកម្រិតក្រុមសម្របសម្រួល ជូនដល់គណៈកម្មការកែទម្រង់ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន។

៤. ធានាថាផែនការសកម្មភាពទាំងអស់របស់អគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពនានា ដែលស្ថិតនៅក្នុងក្រុមសម្របសម្រួលមានសង្គតិភាពនឹងគ្នា ។

៥. កំណត់ផែនការសកម្មភាពដែលប្រទាក់ក្រឡាគ្នានៅក្នុងក្រុមសម្របសម្រួលមួយទៅក្រុមសម្របសម្រួលមួយផ្សេងទៀត និងធ្វើការទំនាក់ទំនងជាមួយគ្នាដើម្បីចាត់វិធានការណ៍សមស្របដើម្បីអនុវត្ត។

៦. ចូលរួមនៅក្នុងក្រុមការងារគ្រប់គ្រងជំនួយបច្ចេកទេស ដើម្បីត្រួតពិនិត្យលើផែនការលទ្ធកម្មសម្រាប់ជ្រើសរើសជំនាញការ ឬទីប្រឹក្សា និងការបំពេញការងាររបស់ជំនាញការ ឬទីប្រឹក្សាទាំងនោះ ។

៧. ធ្វើការវាយតម្លៃជាប្រចាំចំពោះការអនុវត្តរបស់ អគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពនានា ដើម្បីធានាថា ការអនុវត្តកម្មវិធីកែទម្រង់បានឆ្លើយតបទៅនឹងសូចនាករ និងទិសដៅដែលបានគ្រោងទុក។

## II - ភារៈទទួលខុសត្រូវ

១. រៀបចំវិធីសាស្ត្រសមស្របសម្រាប់ក្រុមសម្របសម្រួលនីមួយៗ សម្រាប់ប្រើប្រាស់ក្នុងការវាយតម្លៃទៅលើផែនការសកម្មភាពដែលបានអនុវត្ត ថាតើបានឆ្លើយតបទៅនឹងគោលបំណងនៃកម្មវិធីកែទម្រង់ដែរឬទេ ។

២. ពិនិត្យ និងកែសម្រួលផែនការសកម្មភាពរបស់ អគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពនានា ដោយមានការពិគ្រោះយោបល់ជាមួយលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីធានាថាផែនការសកម្មភាពទាំងនោះបានឆ្លើយតបទៅនឹងគោលបំណងរួមនៃកម្មវិធីកែទម្រង់ទាំងមូល។

៣. បញ្ជូនផែនការសកម្មភាពត្រឡប់ទៅអគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពនានាវិញ ដោយពិគ្រោះយោបល់ជាមួយលេខាធិការដ្ឋានគណកម្មាធិការដឹកនាំការងារកែទប្រង់ ដើម្បី កែសម្រួលក្នុងករណីចាំបាច់ ។

៤. វាយតម្លៃលើរបាយការណ៍វឌ្ឍនភាពរបស់ អគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពនានា ដើម្បីធានាថា របាយការណ៍នោះបានរៀបចំត្រឹមត្រូវ និងទាន់ពេលវេលាដែលបានកំណត់នៅក្នុងផែនការសកម្មភាព ។

៥. រាយការណ៍ជូនគណៈកម្មការកែទម្រង់ជាបន្ទាន់ ក្នុងករណីដែលមានផែនការ សកម្មភាពណាមួយមិនត្រូវបានអនុវត្តតាមពេលវេលាកំណត់ ហើយដែលអាចប៉ះពាល់ជាអវិជ្ជមាន ដល់ការសម្រេចបាននៃគោលបំណងរួមរបស់កម្មវិធីកែទម្រង់ ។

៦. ធានាថាអគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពនានា ឆ្លើយតបបានទាន់ពេលវេលា និងមានប្រសិទ្ធភាព ចំពោះអនុសាសន៍/ការផ្តល់យោបល់ /សំណើរបស់អ្នកជំនាញការ/ទីប្រឹក្សា ។

៧. ធានាឱ្យមានការយល់ច្បាស់អំពីផែនការសកម្មភាពដែលត្រូវអនុវត្តរបស់ អគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពនានា ដែលត្រូវរួមចំណែកដល់ការសម្រេចបាននូវសូចនាករសមិទ្ធកម្មនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

## III - សិទ្ធិអំណាច

១. ក្រុមសម្របសម្រួលមានសិទ្ធិកោះប្រជុំអគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពនានាជាប្រចាំ និងតាមភាពចាំបាច់ ដើម្បីបំពេញតួនាទី និងការទទួលខុសត្រូវខាងលើ។

២. ជំរុញអគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពនានា រៀបចំរបាយការណ៍វឌ្ឍនភាពឱ្យបានទៀងទាត់ពេលវេលា និងត្រឹមត្រូវតាមទម្រង់ដែលបានកំណត់ ។

៣. ជំរុញអគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពនានា ដើម្បីចាត់វិធានការកែតម្រូវក្នុងករណីដែលការអនុវត្តមិនបានឆ្លើយតបតាមពេលវេលាដែលបានកំណត់នៅក្នុងផែនការសកម្មភាព ឬមិនបានឆ្លើយតបទៅនឹងគោលបំណងរួមនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

៤. ស្នើសុំការពន្យល់ពីលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ ក្នុងករណីដែលការស្នើសុំជំនួយបច្ចេកទេសរបស់អគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពនានា មិនបានឆ្លើយតបតាមពេលវេលាត្រូវការ និងស្វះស្វែងរកមធ្យោបាយដើម្បីពន្លឿនការជ្រើសរើសអ្នកជំនាញការ/ទីប្រឹក្សាឱ្យបានឆាប់រហ័ស ។

៥. ពិនិត្យលើផែនការថវិការបស់អគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពនានា សម្រាប់អនុវត្តផែនការសកម្មភាពដើម្បីដាក់ជូនប្រធានគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រេច។

៦. ពិនិត្យសំណើបង្វែថវិកាសម្រាប់គាំទ្រសកម្មភាពជាអាទិភាពក្នុងឆ្នាំ ដោយជូនដំណឹងដល់លេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ និងអនុលោមតាមវិធានដែលបានឯកភាពជាមួយដៃគូអភិវឌ្ឍន៍ និងដាក់សំណើនេះជូន ប្រធានគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រេច។

៧. សម្របសម្រួលជាមួយអគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពនានា ក្នុងការកំណត់តម្រូវការបុគ្គលិកសម្រាប់ចូលរួមអនុវត្តកម្មវិធីកែទម្រង់។

*******